# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

របាយការណ៍ហិរញ្ញវត្ថុ
សង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ
3ខែ និង 9ខែ ដែលបានបញ្ចប់
ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021
និង
របាយការណ៍របស់សវនករឯករាជ្យ
ស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ
សង្ខេបចន្លោះពេល

# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ក្រុមហ៊ុន | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក | |
| លេខចុះបញ្ជីពាណិជ្ជកម្ម | 00001157 | |
| ទីស្នាក់ការចុះបញ្ជី | អគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទួលទំពូង 2<br>ខណ្ឌចំការមន<br>រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា | |
| ភាគហ៊ុនិក | *ភាគហ៊ុនិកពីមុន៖*<br>Kookmin Bank Co., Ltd<br>LOLC International Private Limited<br>The Bank of East Asia, Limited<br>ក្រុមហ៊ុន បុគ្គលិកប្រាសាក់លីមីតធីត<br><br>*ភាគហ៊ុនិកថ្មី (អនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021)៖*<br>Kookmin Bank Co., Ltd<br>ធនាគារគូកមីន កម្ពុជា ភីអិលស៊ី | |
| ក្រុមប្រឹក្សាភិបាល | លោក Kwi Sang Jun | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក Ji Kyu Jang | អភិបាល |
| | លោក Choi Dong Hyun | អភិបាល (តែងតាំងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| | លោក Lee Kyung Cheon | អភិបាលឯករាជ្យ<br>(តែងតាំងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| | លោក Pak Jaehong | អភិបាលឯករាជ្យ<br>(តែងតាំងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| | លោក ច័ន្ទ សុផល | អភិបាលឯករាជ្យ<br>(តែងតាំងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| | លោក Ishara Chinthaka Nanayakkara | អភិបាល (លាលែងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| | លោក ស៊ឹម សេនាជាតិ | អភិបាល (លាលែងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| | លោក Minki Brian Hong | អភិបាល (លាលែងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| | លោក Hak Soo Kim | អភិបាល (លាលែងនៅថ្ងៃទី 28 ខែមករា ឆ្នាំ 2021) |

# ព័ត៌មានអំពីក្រុមហ៊ុន (ត)

| | | |
|---|---|---|
| គណៈកម្មាធិការប្រតិបត្តិ | លោក ស៊ីម សេនាជាតិ | ប្រធាននាយកប្រតិបត្តិ |
| | លោក អ៊ុំ សូផន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ |
| | លោក អ៊ុំ សមអឿន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកប្រតិបត្តិការ |
| | លោក នាង សុខឃីម | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក គ្រប់គ្រងអាជីវកម្ម |
| | លោក សាយ សូនី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក គ្រប់គ្រងទីផ្សារ |
| | លោក ជួប វាសនា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក ធនធានមនុស្ស |
| | លោក ជា ហាង | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក ផែនការយុទ្ធសាស្ត្រ និងអាជីវកម្ម |
| សវនករ | ខេភីអឹមជី ខេមបូឌា | |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក**

# មាតិកា


| | |
|---|---|
| | ទំព័រ |
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 – 7 |
| របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 8 – 9 |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 10 |
| របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល | 11 – 12 |
| របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | 13 |
| របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល | 14 – 15 |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 16 – 70 |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ("ក្រុមប្រឹក្សាភិបាល" ឬ"អភិបាល") នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ("ក្រុមហ៊ុន") សូមធ្វើការបង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 9ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021។

## ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណ និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចុះបញ្ជីពាណិជ្ជកម្មជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00001157 ចុះថ្ងៃទី19 ខែកញ្ញា ឆ្នាំ2011 និងដែលបានចុះបញ្ជីសារជាថ្មី នាថ្ងៃទី28 ខែមេសា ឆ្នាំ2016។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុដល់ក្រុមហ៊ុន ដែលមានសុពលភាពចាប់ពីថ្ងៃទី14 ខែធ្នូ ឆ្នាំ2007។ លើសពីនេះទៅទៀត ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ នៅថ្ងៃទី27 ខែសីហា ឆ្នាំ2010 និងការអនុញ្ញាតឲ្យដំណើរការម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ និងសេវាកម្មបង់ប្រាក់តាមម៉ាស៊ីនឆូតកាតនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2011។

ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទួលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## សកម្មភាពអាជីវកម្មចម្បង

ក្រុមហ៊ុនធ្វើប្រតិបត្តិការក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀត ដល់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាសហគ្រាសធុនតូច និងមធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងទាំងនេះ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 9ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ភាគលាភ

ពុំមានការប្រកាសបែងចែក ឬទូទាត់ភាគលាភនៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ ហើយក្រុមប្រឹក្សាភិបាលក៏មិនផ្តល់អនុសាសន៍ឲ្យមានការទូទាត់ភាគលាភ នាកាលបរិច្ឆេទនៃរបាយការណ៍នេះដែរ។

## ដើមទុន

នៅថ្ងៃទី12 ខែឧសភា ឆ្នាំ2021 ក្រុមហ៊ុនបានស្នើសុំទៅធនាគារជាតិនៃកម្ពុជាដើម្បីបង្កើនដើមទុនរបស់ខ្លួនពី 230,000,000 ដុល្លារអាមេរិកទៅ 300,000,000 ដុល្លារអាមេរិក តាមរយៈការធ្វើមូលធនកម្មលើប្រាក់ចំណេញរក្សាទុក។ សំណើរនេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី31 ខែឧសភា ឆ្នាំ2021។ អនុស្សារណៈ និងលក្ខន្តិកៈក្រុមហ៊ុន ត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនេះ ហើយទទួលបានការយល់ព្រមពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី9 ខែមិថុនា ឆ្នាំ2021។

នៅថ្ងៃទី6 ខែកញ្ញា ឆ្នាំ2021 ម្ចាស់ភាគហ៊ុនិកបានព្រមព្រៀងគ្នា ហើយសម្រេចអនុម័តលើការផ្ទេរជាកញ្ចប់នៃភាគហ៊ុនធម្មតារបស់ក្រុមហ៊ុនចំនួន 30% ពី LOLC International Private Limited ("LOLC") The Bank of East Asia, Limited ("BEA") និងក្រុមហ៊ុនបុគ្គលិកប្រាសាក់លីមីតធីត ("PSCo") ទៅឲ្យ Kookmin Bank Co., Ltd ("KB") និងធនាគារគូកមីនកម្ពុជា ភីអិលស៊ី ("KBC")។ ក្រុមហ៊ុនទទួលបានការអនុម័តពីធនាគារជាតិនៃកម្ពុជា ទាក់ទិននឹងការផ្ទេរដើមទុននេះនៅថ្ងៃទី12 ខែតុលា ឆ្នាំ2021។ អនុស្សារណៈ និងលក្ខន្តិកៈក្រុមហ៊ុន ត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនេះ ហើយទទួលបានការយល់ព្រមពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី19 ខែតុលា ឆ្នាំ2021។

ព័ត៌មានលម្អិត នៃការផ្ទេរដើមទុននេះមានដូចខាងក្រោមៈ

| | *ក្រោយពេលផ្ទេរ* | | | *មុនពេលផ្ទេរ* | | |
|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *%* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *%* |
| KB | 299,999,999 | 1,199,996,000 | 100.00 | 210,000,000 | 840,000,000 | 70.00 |
| KBC | 1 | 4,000 | 00.00 | - | - | - |
| LOLC | - | - | - | 63,000,000 | 252,000,000 | 21.00 |
| BEA | - | - | - | 18,900,000 | 75,600,000 | 6.30 |
| PSCo | - | - | - | 8,100,000 | 32,400,000 | 2.70 |
| | 300,000,000 | 1,200,000,000 | 100.00 | 300,000,000 | 1,200,000,000 | 100.00 |

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធននៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

### ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទានទៅអតិថិជន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនត្រូវបានរៀបចំ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានាដើម្បីធ្វើឲ្យប្រាកដថា សកម្មភាពផ្សេងៗត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា ឥណទានអាក្រក់ត្រូវបានលុបចេញពីបញ្ជី ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទាន។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចនឹងបណ្តាលឲ្យចំនួននៃឥណទានអាក្រក់ដែលលុបចេញពីបញ្ជី ឬចំនួននៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

### ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល បានចាត់វិធានការ ដែលមានមូលដ្ឋានសមហេតុផលដើម្បីធ្វើឲ្យប្រាកដថា បណ្តាទ្រព្យសកម្ម (លើកលែងបំណុល) ដែលទំនងជាមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្ម តាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលបានរំពឹងទុកថាអាចប្រមូលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

### វិធីសាស្រ្តនៃការវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើងបានធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្រ្តដែលមានស្រាប់ ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

### បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- ពុំមានការដាក់បញ្ចាំលើទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលបានយកមកប្រើប្រាស់សម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមក និង
- ពុំមានបំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## បំណុលយថាភាព និងបំណុលផ្សេងៗ (ត)

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវបានទាមទារឲ្យសង ឬអាចនឹងទាមទារឲ្យសងក្នុងអំឡុងការិយបរិច្ឆេទ បន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍នេះ ដែលនឹងបង្កឲ្យមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ។

## ការប្រែប្រួលនៃកាលៈទេសៈ

នាការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុនេះ មិនរងផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីចុងកាលបរិច្ឆេទរាយការណ៍មកទល់នឹងការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតី ដែលអាចបណ្តាលឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក Kwi Sang Jun | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Ji Kyu Jang | អភិបាល |
| លោក Choi Dong Hyun | អភិបាល (តែងតាំងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| លោក Lee Kyung Cheon | អភិបាលឯករាជ្យ (តែងតាំងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| លោក Pak Jaehong | អភិបាលឯករាជ្យ (តែងតាំងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| លោក ច័ន្ទ សុផល | អភិបាលឯករាជ្យ (តែងតាំងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| លោក Ishara Chinthaka Nanayakkara | អភិបាល (លាលែងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| លោក ស៊ឹម សេនាជាតិ | អភិបាល (លាលែងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| លោក Minki Brian Hong | អភិបាល (លាលែងនៅថ្ងៃទី 12 ខែតុលា ឆ្នាំ 2021) |
| លោក Hak Soo Kim | អភិបាល (លាលែងនៅថ្ងៃទី 28 ខែមករា ឆ្នាំ 2021) |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## គណៈគ្រប់គ្រងប្រតិបត្តិ

សមាជិកគណៈគ្រប់គ្រងប្រតិបត្តិនៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក ស៊ឹម សេនាជាតិ | ប្រធាននាយកប្រតិបត្តិ |
| លោក អ៊ុំ សូផន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ |
| លោក អ៊ុំ សមអឿន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកប្រតិបត្តិការ |
| លោក នាង សុខឃីម | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងអាជីវកម្ម |
| លោក សាយ សូនី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងទីផ្សារ |
| លោក ជួប វាសនា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស |
| លោក ជា ហាង | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកផែនការយុទ្ធសាស្រ្ត និងអាជីវកម្ម |

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកនៃក្រុមប្រឹក្សាភិបាលណាម្នាក់ មានភាគកម្មដោយផ្ទាល់ក្នុងមូលធនរបស់ក្រុមហ៊ុនឡើយ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលមានក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់លទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬរបស់សាជីវកម្មដទៃឡើយ។

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬជាមួយនឹងក្រុមហ៊ុនដែលមានអភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនណាមួយដែលអភិបាលនោះ មានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះឡើយ លើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ក្រុមប្រឹក្សាភិបាល មានភារៈទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុននាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021 និងសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែនិង 9ខែ ដែលបានបញ្ចប់ ដូចបានបង្ហាញនៅទំព័រទី 10 ដល់ទី 70 ត្រូវបានរៀបចំឡើងជាសារវន្ត ដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* ("ស.គ.អ.ក 34")។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)

ក្រុមប្រឹក្សាភិបាល ត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលធ្វើឡើងដោយគណៈគ្រប់គ្រង ដែលត្រូវបានតម្រូវឲ្យ៖

- អនុម័តនូវគោលនយោបាយគណនេយ្យសមស្របនានា ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងដោយភាពប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។
- អនុលោមតាមលក្ខខណ្ឌតម្រូវនៃការលាតត្រដាងព័ត៌មាន និងការណែនាំផ្សេងៗ ដែលចេញផ្សាយដោយ ស.គ.អ.ក 34 ឬប្រសិនបើមានវៀចចាកពីការបង្ហាញព័ត៌មានដ៏សមស្រប គឺត្រូវធ្វើឲ្យប្រាកដថា ការវៀចចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឲ្យបានសមស្របក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។
- រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែវាមានភាពមិនសមស្របមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងអាចបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតបាន។
- បង្កើតគោលការណ៍ជារួមសម្រាប់ក្រុមហ៊ុន អនុម័តរាល់សេចក្តីសម្រេច និងសកម្មភាពទាំងឡាយធ្វើឡើងដោយគណៈគ្រប់គ្រង ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយត្រូវធានាថាគោលនយោបាយ និងសេចក្តីសម្រេចទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវក្នុងការរក្សាទុកបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ (រួមទាំងភាពច្បាស់លាស់នៃបញ្ជីនេះ នៅគ្រប់ពេលវេលា) ដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងត្រូវធានាថា បញ្ជីគណនេយ្យបានអនុលោមតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រងក៏មានភារៈទទួលខុសត្រូវផងដែរចំពោះការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងចាត់វិធានការសមស្របនានា ដើម្បីទប់ស្កាត់ និងស្វែងរកការក្លែងបន្លំ និងភាពមិនប្រក្រតី។

ក្រុមប្រឹក្សាភិបាលបានអះអាងថា គណៈគ្រប់គ្រងបានអនុវត្តតាមលក្ខខណ្ឌតម្រូវខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល រួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ ថាត្រូវបានរៀបចំឡើង គ្រប់ទិដ្ឋភាពជាសារវន្ត ដោយអនុលោមទៅតាម ស.គ.អ.ក 34។

*ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។*

លោក Kwi Sang Jun

*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី11 ខែវិច្ឆិកា ឆ្នាំ2021

KPMG

KPMG Cambodia Ltd
4th Floor, Delano Center
No. 144, Street 169, Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia
+855 23 216 899 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

## ជូនចំពោះភាគទុនិករបស់
## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

### *សេចក្តីផ្តើម*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021 របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល និងរបាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 9ខែ ដែលបានបញ្ចប់ របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 9ខែ ដែលបានបញ្ចប់ និងកំណត់សម្គាល់ពន្យល់ផ្សេងៗទៀត ដែលបានបង្ហាញនៅទំព័រទី 10 ដល់ទី 70 ហៅកាត់ថា ("របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល")។

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 "*របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*"។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺផ្តល់ការសន្និដ្ឋានលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយផ្អែកលើការធ្វើការត្រួតពិនិត្យរបស់យើងខ្ញុំ។

### *វិសាលភាពនៃការត្រួតពិនិត្យ*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិនៃកម្ពុជាសម្រាប់កិច្ចការងារត្រួតពិនិត្យលេខ 2410 ស្តីពី "*ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន*"។ ការត្រួតពិនិត្យលើពត៌មានហិរញ្ញវត្ថុចន្លោះពេល រួមមានការសាកសួរព័ត៌មាន ជាពិសេសសាកសួរបុគ្គលដែលមានភារៈទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុ ហើយធ្វើការវិភាគ និងអនុវត្តនូវនីតិវិធីត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យ មានវិសាលភាពតូចជាងការធ្វើសវនកម្ម ដែលអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ហេតុដូច្នេះ ការត្រួតពិនិត្យមិនអាចឲ្យយើងខ្ញុំ ផ្តល់នូវអំណះអំណាងថា យើងខ្ញុំបានដឹងនូវរាល់បញ្ហាជាសារវន្តទាំងឡាយ ដែលអាចនឹងត្រូវបានរកឃើញក្នុងពេលធ្វើសវនកម្មនោះឡើយ។ ហេតុដូច្នេះយើងខ្ញុំ មិនបញ្ចេញមតិសវនកម្មនោះទេ។

KPMG Cambodia Ltd., a Cambodian single member private limited company and a member firm of the KPMG global organization of independent member firms affiliated with KPMG International Limited, a private English company limited by guarantee. All rights reserved.

KPMG

### *សេចក្តីសន្និដ្ឋាន*

ផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ ពុំមានបញ្ហាណាមួយដែលបានទាញចំណាប់អារម្មណ៍យើងខ្ញុំ ដែលបណ្តាលឲ្យយើងខ្ញុំជឿថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនត្រូវបានរៀបចំជាសារវន្ត ស្របតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *("របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល")* នោះឡើយ។

### *ការទាញចំណាប់អារម្មណ៍*

យើងខ្ញុំសូមទាញចំណាប់អារម្មណ៍ទៅលើកំណត់សម្គាល់ 35 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលបញ្ជាក់ពីការរាយការណ៍ឡើងវិញនូវព័ត៌មានប្រៀបធៀបដែលបានដាក់បង្ហាញនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020។ សេចក្តីសន្និដ្ឋានរបស់យើងខ្ញុំមិនត្រូវបានកែប្រែដោយសារបញ្ហានេះទេ។

### *បញ្ហាផ្សេងៗ*

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 9ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 គឺត្រូវបានធ្វើការត្រួតពិនិត្យដោយសវនករឯករាជ្យផ្សេង ដោយបានបញ្ចេញសេចក្តីសន្និដ្ឋានមិនមានបញ្ហានៅថ្ងៃទី12 ខែវិច្ឆិកា ឆ្នាំ2020។ លើសពីនេះ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ដោយមិនរាប់បញ្ចូលការធ្វើនិយ័តកម្មដូចដែលបានព័ណ៌នានៅក្នុងកំណត់សម្គាល់ 35 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺត្រូវបានរងសវនកម្មដោយសវនករឯករាជ្យតែមួយ ដោយបានបញ្ចេញមតិនៅថ្ងៃទី31 ខែមីនា ឆ្នាំ2021 ថារបាយការណ៍ហិរញ្ញវត្ថុនោះមានភាពត្រឹមត្រូវ។

ជាផ្នែកមួយនៃការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021 និងសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 9ខែ ដែលបានបញ្ចប់ យើងខ្ញុំបានត្រួតពិនិត្យលើការធ្វើនិយ័តកម្មដែលត្រូវបានយកមកអនុវត្តដើម្បីរាយការណ៍ឡើងវិញនូវព័ត៌មានប្រៀបធៀបនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ដូចដែលបានព័ណ៌នានៅក្នុងកំណត់សម្គាល់ 35 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។ យើងខ្ញុំមិន ត្រូវបានតម្រូវឲ្យធ្វើការត្រួតពិនិត្យឡើងវិញ ឬអនុវត្តនីតិវិធីណាមួយទៅលើរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 នោះឡើយ ក្រៅតែពីការធ្វើនិយ័តកម្ម ដែលបានព័ណ៌នានៅក្នុងកំណត់សម្គាល់ 35 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។ ហេតុដូច្នេះហើយ យើងខ្ញុំមិនបញ្ចេញសេចក្តីសន្និដ្ឋាន ឬទម្រង់នៃការអះអាងណាមួយ លើរបាយការណ៍ហិរញ្ញវត្ថុទាំងមូលនោះឡើយ។ យ៉ាងណាមិញ ជាការសន្និដ្ឋានរបស់យើងខ្ញុំ ការធ្វើនិយ័តកម្ម ដូចបានព័ណ៌នានៅក្នុងកំណត់សម្គាល់ 35 គឺមានភាពសមស្រប ហើយត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

**ង៉ៃ ហ៊ុយ**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី11 ខែវិច្ឆិកា ឆ្នាំ2021

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## នាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021

| | | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020* | |
|---|---|---|---|---|---|
| | *កំណត់សម្គាល់* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក (ការរាយការណ៍ឡើងវិញ)* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4) (ការរាយការណ៍ឡើងវិញ)* |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 6 | 190,898,835 | 778,676,348 | 160,578,086 | 649,538,358 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 7 | 309,676,208 | 1,263,169,252 | 438,355,399 | 1,773,147,589 |
| សមតុល្យនៅធនាគារផ្សេងៗ | 8 | 5,572,819 | 22,731,529 | 3,975,029 | 16,078,992 |
| ឥណទានផ្តល់ដល់អតិថិជន | 9 | 3,534,562,656 | 14,417,481,074 | 2,978,579,934 | 12,048,355,833 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 2,398,663 | 9,784,145 | 1,341,096 | 5,424,733 |
| ទ្រព្យ និងបរិក្ខារ | 11 | 5,110,577 | 20,846,044 | 5,662,803 | 22,906,039 |
| សិទ្ធប្រើប្រាស់ទ្រព្យសកម្ម | 12 | 13,947,552 | 56,892,065 | 15,322,179 | 61,978,214 |
| ទ្រព្យសកម្មអរូបី | 13 | 1,429,450 | 5,830,727 | 1,607,168 | 6,500,995 |
| ពន្ធពន្យារសុទ្ធជាទ្រព្យសកម្ម | 20(គ) | 12,455,433 | 50,805,711 | 10,904,851 | 44,110,122 |
| **ទ្រព្យសកម្មសរុប** | | **4,076,052,193** | **16,626,216,895** | **3,616,326,545** | **14,628,040,875** |
| **បំណុល និងមូលធនម្ចាស់ភាគហ៊ុន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើពីធនាគារនានា និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | 14 | 76,413,087 | 311,688,982 | 37,232,817 | 150,606,745 |
| ប្រាក់បញ្ញើរបស់អតិថិជន | 15 | 2,380,024,093 | 9,708,118,275 | 2,074,680,943 | 8,392,084,414 |
| ប្រាក់កម្ចី | 16 | 775,080,615 | 3,161,553,829 | 794,430,317 | 3,213,470,632 |
| មូលបត្របំណុលត្រូវសង | 17 | 31,938,145 | 130,275,693 | 30,666,038 | 124,044,124 |
| អនុបំណុល | 18 | 122,869,770 | 501,185,792 | 113,667,817 | 459,786,320 |
| បំណុលភតិសន្យា | 19 | 13,191,117 | 53,806,566 | 14,424,818 | 58,348,389 |
| បំណុលពន្ធលើប្រាក់ចំណេញ | 20(ខ) | 26,322,967 | 107,371,382 | 24,076,695 | 97,390,231 |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | 21 | 1,502,962 | 6,130,582 | 435,375 | 1,761,092 |
| បំណុលផ្សេងៗ | 22 | 14,518,099 | 59,219,326 | 7,873,601 | 31,848,716 |
| **បំណុលសរុប** | | **3,441,860,855** | **14,039,350,427** | **3,097,488,421** | **12,529,340,663** |
| **មូលធនម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | 23(ក) | 300,000,000 | 1,200,000,000 | 230,000,000 | 920,000,000 |
| ប្រាក់ចំណេញរក្សាទុក | | 326,966,550 | 1,338,238,886 | 285,224,840 | 1,163,897,093 |
| ទុនបម្រុង | 23(ខ) | 3,195,917 | 12,951,937 | 3,151,952 | 12,773,175 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 23(គ) | 4,028,871 | 16,283,741 | 461,332 | 1,778,127 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | 19,391,904 | - | 251,817 |
| **មូលធនម្ចាស់ភាគហ៊ុនសរុប** | | **634,191,338** | **2,586,866,468** | **518,838,124** | **2,098,700,212** |
| **បំណុល និងមូលធនម្ចាស់ភាគហ៊ុនសរុប** | | **4,076,052,193** | **16,626,216,895** | **3,616,326,545** | **14,628,040,875** |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 9ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021

| | | *សម្រាប់ដំណាច់ ការិយបរិច្ឆេទ 9ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021* | | *សម្រាប់ដំណាច់ ការិយបរិច្ឆេទ 9ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020* | |
|---|---|---|---|---|---|
| | *កំណត់សម្គាល់* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| ចំណូលការប្រាក់ | 24 | 373,371,559 | 1,518,128,759 | 314,804,576 | 1,285,032,279 |
| ចំណាយការប្រាក់ | 25 | (154,428,206) | (627,905,086) | (149,395,996) | (609,834,456) |
| **ចំណូលការប្រាក់សុទ្ធ** | | **218,943,353** | **890,223,673** | **165,408,580** | **675,197,823** |
| ចំណូលកម្រៃជើងសា | 26 | 6,943,087 | 28,230,592 | 4,555,329 | 18,594,853 |
| ចំណាយកម្រៃជើងសា | 26 | (97,656) | (397,069) | (142,070) | (579,930) |
| **ចំណូលសុទ្ធពីកម្រៃជើងសា និងប្រាក់កម្រៃ** | 26 | **6,845,431** | **27,833,523** | **4,413,259** | **18,014,923** |
| ចំណូលផ្សេងៗ | 27 | 7,662,360 | 31,155,156 | 6,752,655 | 27,564,338 |
| ចំណូលវិភាគទាន | | 1,175,639 | 4,780,148 | 589,545 | 2,406,523 |
| (ខាត)/ចំណេញសុទ្ធពីការប្តូររូបិយប័ណ្ណ | | (1,132,780) | (4,605,883) | 290,939 | 1,187,613 |
| **ចំណូលផ្សេងៗសរុប** | | **7,705,219** | **31,329,421** | **7,633,139** | **31,158,474** |
| **ចំណូលសរុបពីការប្រាក់ កម្រៃជើងសា និងចំណូលផ្សេងៗ** | | **233,494,003** | **949,386,617** | **177,454,978** | **724,371,220** |
| ចំណាយលើបុគ្គលិក | 28 | (56,362,415) | (229,169,579) | (52,441,424) | (214,065,893) |
| សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃ | 9 | (18,495,950) | (75,204,533) | (29,799,480) | (121,641,477) |
| ចំណាយទូទៅ និងរដ្ឋបាល | 29 | (10,170,952) | (41,355,091) | (11,803,888) | (48,183,471) |
| រំលស់ | 30 | (4,922,036) | (20,012,998) | (4,888,677) | (19,955,580) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | **143,542,650** | **583,644,416** | **78,521,509** | **320,524,799** |
| ចំណាយពន្ធលើប្រាក់ចំណេញ | 20(ក) | (28,189,436) | (114,618,247) | (15,740,653) | (64,253,346) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **115,353,214** | **469,026,169** | **62,780,856** | **256,271,453** |
| *លទ្ធផលលម្អិតផ្សេងៗ៖* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 19,140,087 | - | 11,380,286 |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | **115,353,214** | **488,166,256** | **62,780,856** | **267,651,739** |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021

| | | *សម្រាប់ដំណាច់ ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021* | | *សម្រាប់ដំណាច់ ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020* | |
|---|---|---|---|---|---|
| | *កំណត់សម្គាល់* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| ចំណូលការប្រាក់ | 24 | 131,252,821 | 534,986,498 | 107,644,290 | 440,803,368 |
| ចំណាយការប្រាក់ | 25 | (52,869,081) | (215,494,374) | (51,032,296) | (208,977,252) |
| **ចំណូលការប្រាក់សុទ្ធ** | | **78,383,740** | **319,492,124** | **56,611,994** | **231,826,116** |
| ចំណូលកម្រៃជើងសា | 26 | 2,608,668 | 10,632,931 | 2,085,496 | 8,540,106 |
| ចំណាយកម្រៃជើងសា | 26 | (19,768) | (80,574) | (79,784) | (326,715) |
| **ចំណូលសុទ្ធពីកម្រៃជើងសា និងប្រាក់កម្រៃ** | 26 | **2,588,900** | **10,552,357** | **2,005,712** | **8,213,391** |
| ចំណូលផ្សេងៗ | 27 | 2,507,346 | 10,219,942 | 2,150,525 | 8,806,400 |
| ចំណូលវិភាគទាន | | 419,935 | 1,711,655 | 331,529 | 1,357,611 |
| (ខាត)/ចំណេញសុទ្ធពីការប្តូររូបិយប័ណ្ណ | | (540,002) | (2,201,048) | 330,605 | 1,353,827 |
| **ចំណូលផ្សេងៗសរុប** | | **2,387,279** | **9,730,549** | **2,812,659** | **11,517,838** |
| **ចំណូលសរុបពីការប្រាក់ កម្រៃជើងសា និងចំណូលផ្សេងៗ** | | **83,359,919** | **339,775,030** | **61,430,365** | **251,557,345** |
| ចំណាយលើបុគ្គលិក | 28 | (18,513,832) | (75,462,379) | (17,745,080) | (72,666,103) |
| សំវិធានធនលើការខាតបង់នៃឱនភាពនៃតម្លៃ | 9 | (1,695,052) | (6,909,032) | (6,292,408) | (25,767,411) |
| ចំណាយទូទៅ និងរដ្ឋបាល | 29 | (3,201,930) | (13,051,068) | (3,939,557) | (16,132,486) |
| រំលស់ | 30 | (1,666,704) | (6,793,486) | (1,692,253) | (6,929,776) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | **58,282,401** | **237,559,065** | **31,761,067** | **130,061,569** |
| ចំណាយពន្ធលើប្រាក់ចំណេញ | 20(ក) | (11,404,754) | (46,485,777) | (6,353,724) | (26,018,500) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **46,877,647** | **191,073,288** | **25,407,343** | **104,043,069** |
| *លទ្ធផលលម្អិតផ្សេងៗ៖* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 2,616,286 | - | 3,364,768 |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | **46,877,647** | **193,689,574** | **25,407,343** | **107,407,837** |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 9ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុង | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ2021 (ការរាយការណ៍ឡើងវិញ) | 230,000,000 | 920,000,000 | 285,224,840 | 1,163,897,093 | 3,151,952 | 12,773,175 | 461,332 | 1,778,127 | - | 251,817 | 518,838,124 | 2,098,700,212 |
| មូលធនកម្មលើប្រាក់ចំណេញរក្សាទុក | 70,000,000 | 280,000,000 | (70,000,000) | (280,000,000) | - | - | - | - | - | - | - | - |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 115,353,214 | 469,026,169 | - | - | - | - | - | - | 115,353,214 | 469,026,169 |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (3,567,539) | (14,505,614) | - | - | 3,567,539 | 14,505,614 | - | - | - | - |
| ការផ្ទេរទៅទុនបម្រុង | - | - | (43,965) | (178,762) | 43,965 | 178,762 | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | 19,140,087 | - | 19,140,087 |
| **សមតុល្យនាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021** | **300,000,000** | **1,200,000,000** | **326,966,550** | **1,338,238,886** | **3,195,917** | **12,951,937** | **4,028,871** | **16,283,741** | **-** | **19,391,904** | **634,191,338** | **2,586,866,468** |
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ2020 (ការរាយការណ៍ឡើងវិញ) | 230,000,000 | 920,000,000 | 174,271,385 | 711,503,244 | 3,093,332 | 12,534,181 | 2,644,420 | 10,715,190 | - | 16,034,618 | 410,009,137 | 1,670,787,233 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 62,780,856 | 256,271,453 | - | - | - | - | - | - | 62,780,856 | 256,271,453 |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | 2,644,420 | 10,715,190 | - | - | (2,644,420) | (10,715,190) | - | - | - | - |
| ការផ្ទេរទៅទុនបម្រុង | - | - | (43,965) | (179,465) | 43,965 | 179,465 | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | 11,380,286 | - | 11,380,286 |
| **សមតុល្យនាថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 (ការរាយការណ៍ឡើងវិញ)** | **230,000,000** | **920,000,000** | **239,652,696** | **978,310,422** | **3,137,297** | **12,713,646** | **-** | **-** | **-** | **27,414,904** | **472,789,993** | **1,938,438,972** |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 9ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021

| | | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 9ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021 | | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 9ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពប្រតិបត្តិការ** | 31 | **(114,034,674)** | **(463,664,983)** | **(63,056,959)** | **(257,398,507)** |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | | (995,174) | (4,046,377) | (2,585,827) | (10,555,346) |
| ការទិញទ្រព្យសកម្មអរូបី | | (43,735) | (177,827) | (436,007) | (1,779,781) |
| ការវិនិយោគលើវិញ្ញាបនប័ត្រប្រាក់បញ្ញើ ដែលអាចចរចាបាន | | (147,430) | (599,450) | (147,561) | (602,344) |
| សាច់ប្រាក់បានពីការវិនិយោគលើ វិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចចរចាបាន | | 148,377 | 603,301 | 147,991 | 604,099 |
| សាច់ប្រាក់បានពីការលក់ទ្រព្យ និងបរិក្ខារ | | 63,822 | 259,500 | 10,872 | 44,380 |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ** | | **(974,140)** | **(3,960,853)** | **(3,010,532)** | **(12,288,992)** |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | 203,062,396 | 825,651,702 | 254,086,688 | 1,037,181,860 |
| ការទូទាត់ប្រាក់កម្ចី | | (222,932,103) | (906,441,931) | (319,541,830) | (1,304,369,750) |
| សាច់ប្រាក់បានពីអនុបំណុល | | 17,883,024 | 72,712,376 | - | - |
| ការទូទាត់អនុបំណុល | | (10,302,895) | (41,891,571) | (11,021,684) | (44,990,514) |
| សាច់ប្រាក់បានពីការបោះផ្សាយ មូលបត្របំណុល | | - | - | 30,535,399 | 124,645,499 |
| ការទូទាត់បំណុលភតិសន្យា | | (3,015,025) | (12,259,092) | (2,797,673) | (11,420,101) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពហិរញ្ញប្បទាន** | | **(15,304,603)** | **(62,228,516)** | **(48,739,100)** | **(198,953,006)** |
| **ការថយចុះសុទ្ធ នៃសាច់ប្រាក់ និង សាច់ប្រាក់សមមូល** | | **(130,313,417)** | **(529,854,352)** | **(114,806,591)** | **(468,640,505)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ | | 417,065,787 | 1,687,031,108 | 430,322,406 | 1,753,563,804 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 12,486,161 | - | 8,691,542 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | 6 | **286,752,370** | **1,169,662,917** | **315,515,815** | **1,293,614,841** |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021

| | | *សម្រាប់ដំណាច់ ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021* | | *សម្រាប់ដំណាច់ ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020* | |
|---|---|---|---|---|---|
| | *កំណត់សម្គាល់* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| **សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | 31 | **(67,812,373)** | **(276,403,233)** | **(86,258,929)** | **(353,230,313)** |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | | (456,857) | (1,862,149) | (527,810) | (2,161,382) |
| ការទិញទ្រព្យសកម្មអរូបី | | - | - | (21,000) | (85,995) |
| ការវិនិយោគលើវិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចចរចាបាន | | - | - | (147,561) | (604,262) |
| សាច់ប្រាក់បានពីការវិនិយោគលើវិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចចរចាបាន | | 148,377 | 604,785 | 147,559 | 604,254 |
| សាច់ប្រាក់បានពីការលក់ទ្រព្យ និងបរិក្ខារ | | 1,763 | 7,186 | 5,141 | 21,052 |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(306,717)** | **(1,250,178)** | **(543,671)** | **(2,226,333)** |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | 125,301,031 | 510,727,002 | 54,207,405 | 221,979,323 |
| ការទូទាត់ប្រាក់កម្ចី | | (74,999,272) | (305,697,033) | (176,721,568) | (723,674,821) |
| សាច់ប្រាក់បានពីអនុបំណុល | | 586,512 | 2,390,623 | - | - |
| ការទូទាត់អនុបំណុល | | (1,731,686) | (7,058,352) | (655,114) | (2,682,692) |
| ការទូទាត់បំណុលភតិសន្យា | | (1,064,872) | (4,340,418) | (1,018,660) | (4,171,413) |
| **សាច់ប្រាក់សុទ្ធទទួលបាន/(ប្រើប្រាស់ក្នុង) សកម្មភាពហិរញ្ញប្បទាន** | | **48,091,713** | **196,021,822** | **(124,187,937)** | **(508,549,603)** |
| **ការថយចុះសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **(20,027,377)** | **(81,631,589)** | **(210,990,537)** | **(864,006,249)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | | 306,779,747 | 1,250,127,470 | 526,506,352 | 2,154,990,500 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 1,167,036 | - | 2,630,590 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | 6 | **286,752,370** | **1,169,662,917** | **315,515,815** | **1,293,614,841** |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 9ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយ និងត្រូវអានភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## 1. ព័ត៌មានទូទៅ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណ និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុន ត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00001157 នៅថ្ងៃទី19 ខែកញ្ញា ឆ្នាំ2011។ ក្រុមហ៊ុនបានចុះបញ្ជីសារជាថ្មី នៅថ្ងៃទី28 ខែមេសា ឆ្នាំ2016។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណជាមីក្រូហិរញ្ញវត្ថុឲ្យក្រុមហ៊ុន ដែលមានសុពលភាពចាប់ពីថ្ងៃទី14 ខែធ្នូ ឆ្នាំ2007។ លើសពីនេះទៅទៀត ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ នៅថ្ងៃទី27 ខែសីហា ឆ្នាំ2010 និងការអនុញ្ញាតឲ្យដំណើរការម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ និងសេវាកម្មបង់ប្រាក់តាមម៉ាស៊ីនឆូតកាតនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2011។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មហិរញ្ញវត្ថុដល់សហគមន៍ជនបទ និងសហគ្រាសខ្នាតតូចក្នុងប្រទេសកម្ពុជា តាមរយៈការិយាល័យកណ្តាលរបស់ក្រុមហ៊ុន នៅក្នុងរាជធានីភ្នំពេញ និងសាខាជាច្រើនទៀតនៅក្នុងរាជធានីភ្នំពេញ និងខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជា។

ស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទួលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021 ក្រុមហ៊ុនមានបុគ្គលិកចំនួន 9,203 នាក់ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020៖ ចំនួន 9,042 នាក់)។

## 2. មូលដ្ឋានទូទៅនៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ("ស.គ.អ.ក") 34 "*របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*"។ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនបានរួមបញ្ចូលនូវរាល់ព័ត៌មានទាំងស្រុងរបស់របាយការណ៍ហិរញ្ញវត្ថុ តាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជានោះទេ។ យ៉ាងណាមិញ កំណត់សម្គាល់ពន្យល់បន្ថែមដែលបានជ្រើសរើស ត្រូវបានដាក់បញ្ចូលដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការទាំងឡាយដែលមានលក្ខណៈជាសារវន្ត ក្នុងការស្វែងយល់ពីបម្រែបម្រួលនៃស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលរបស់ក្រុមហ៊ុន ចាប់តាំងពីរបាយការណ៍ហិរញ្ញវត្ថុចុងក្រោយនាការិយបរិច្ឆេទ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 9ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (ក) របាយការណ៍អនុលោមភាព (ត)

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានអនុម័ត និងផ្តល់សិទ្ធិបោះផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី11 ខែវិច្ឆិកា ឆ្នាំ2021។

### (ខ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល។ ដោយសារក្រុមហ៊ុន ធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រងក៏បានកំណត់ថាប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ តួលេខទាំងអស់ ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិក ដែលជិតបំផុត លុះត្រាតែមានការបង្ហាញផ្សេងពីនេះ។

### (គ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធនឹងអនាគត។ តាមនិយមន័យ ការប៉ាន់ស្មានគណនេយ្យនឹងកម្រស្មើនឹងលទ្ធផលជាក់ស្តែងដែលពាក់ព័ន្ធ។ ដើម្បីលើកកម្ពស់ខ្លឹមសារព័ត៌មាននៃការប៉ាន់ស្មាន អថេរសំខាន់ៗមួយចំនួន ដែលត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផល និងស្ថានភាពហិរញ្ញវត្ថុចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានធ្វើតេស្តលើរំញោចនៃការផ្លាស់ប្តូរនៃប៉ារ៉ាម៉ែត្រ ដែលជាមូលដ្ឋានក្នុងការប៉ាន់ស្មាន។ ការប៉ាន់ស្មាន និងការសន្មតដែលមានហានិភ័យធ្ងន់ធ្ងរ ដែលអាចបណ្តាលឲ្យមានការកែតម្រូវជាសារវន្តលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបន្ទាប់ ត្រូវបានព័ណ៌នាដូចខាងក្រោម៖

### *(i) ការវិនិច្ឆ័យ*

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានឥទ្ធិពលជាសារវន្ត លើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបញ្ចូលក្នុងកំណត់សម្គាល់ដូចខាងក្រោម។

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (គ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

*(i) ការវិនិច្ឆ័យ (ត)*

- ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃម៉ូឌែលអាជីវកម្មដែលទ្រព្យទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") លើចំនួនប្រាក់ដើមដែលនៅសល់។

- ការកើនឡើងជាសារវន្តចំពោះហានិភ័យឥណទាន៖ ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ថាតើហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូងដែរ ឬទេ ការកំណត់វិធីសាស្ត្រសម្រាប់ការដាក់បញ្ចូលព័ត៌មានរំពឹងទុកនាពេលអនាគត ទៅក្នុងការវាស់វែងលើ ការខាតបង់រំពឹងទុកលើឥណទាន ("ECL") និងការជ្រើសរើស និងការអនុម័តលើម៉ូឌែលសម្រាប់ការវាស់វែង ECL។

*(ii) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន*

- ឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ៖ កំណត់ការបញ្ចូលធាតុចូលទៅក្នុងគំរូនៃការវាស់វែង ECL រួមទាំងការបញ្ចូលព័ត៌មានរំពឹងទុកនាពេលអនាគត។

- ការកំណត់លើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុជាមួយធាតុចូលមិនអាចអង្កេតបានជាសារវន្ត។

- ការទទួលស្គាល់ និងការវាស់វែងយថាភាព៖ ការសន្មតសំខាន់ៗលើភវនីយភាព និងទំហំនៃលំហូរធនធាន។

- ឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ៖ ការសន្មតសំខាន់ៗ ដែលត្រូវបានយកមកប្រើប្រាស់ក្នុងការប៉ាន់ស្មានលើលំហូរទឹកប្រាក់ដែលអាចប្រមូលមកវិញបាន។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 9ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (គ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

*(ii) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន (ត)*

**វីរុសកូវីដ និងផលប៉ះពាល់លើ ECL**

ECL ត្រូវបានប៉ាន់ប្រមាណដោយផ្អែកទៅលើលក្ខខណ្ឌសេដ្ឋកិច្ចមួយចំនួនដែលបានព្យាករណ៍ នាកាលបរិច្ឆេទរាយការណ៍។ ការផ្ទុះឡើងនៃវីរុសឈ្មោះកូរ៉ូណា ("ជំងឺកូវីដ-19") បានរាតត្បាតទូទាំងសកលលោក (រួមបញ្ចូលទាំងប្រទេសចិនដីគោក ប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត) ដែលបានធ្វើឲ្យមានការរាំងស្ទះលើសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ផលប៉ះពាល់ទៅលើផលិតផលក្នុងស្រុកសរុប (GDP) និងសូចនាករសំខាន់ៗផ្សេងទៀត នឹងត្រូវយកមកពិចារណា សម្រាប់ការកំណត់នូវភាពធ្ងន់ធ្ងរ និងភវនីយភាពនៃការធ្លាក់ចុះនៃសេណារីយ៉ូសេដ្ឋកិច្ចនានា ដែលត្រូវបានយកមកប្រើក្នុងការប៉ានស្មាន ECL។ ការប៉ានស្មានរបស់អ្នកគ្រប់គ្រង ត្រូវបានកំណត់ដោយផ្អែកទៅលើសេណារីយ៉ូដែលអាចកើតឡើងនាពេលអនាគត ដោយគិតពីស្ថានភាពជាក់ស្តែង កាលៈទេសៈ និងការព្យាករណ៍នៃស្ថានភាពសេដ្ឋកិច្ចនាពេលអនាគត និងព័ត៌មានគាំទ្រដែលអាចប្រើប្រាស់បាន នាកាលបរិច្ឆេទរាយការណ៍នេះ។

ការគណនា ECL នៅស្ថានភាពបច្ចុប្បន្នអាចមានភាពមិនប្រាកដប្រជាជាសារវន្ត។ អ្នកគ្រប់គ្រងបានធ្វើការព្យាករណ៍ដ៏ប្រសើរបំផុត លើផលប៉ះពាល់របស់វីរុសកូវីដមកលើក្រុមហ៊ុន យ៉ាងណាមិញ ការព្យាករណ៍នេះអាចនឹងប្រែប្រួលជាសារវន្តនៅពេលមានព្រឹត្តិការណ៍ថ្មីៗកើតឡើងជាក់ស្តែង។ ជាលទ្ធផល តួលេខនេះ មិនគួរត្រូវបានយកជាការណែនាំជាក់លាក់ ឬជាការព្យាករណ៍នៃផលប៉ះពាល់ហិរញ្ញវត្ថុចុងក្រោយ ដែលបានរំពឹងទុកនោះទេ។ ក្នុងករណីដែលផលប៉ះពាល់នោះមានសភាពកាន់តែធ្ងន់ធ្ងរ និងមានរយៈពេលយូរជាងការរំពឹងទុក នោះផលប៉ះពាល់ទន្ទឹមគ្នានឹងកើតមានឡើងចំពោះ ECL មកលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលត្រូវបានយកមកអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺដូចគ្នាទៅនឹងគោលនយោបាយដែលបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**
**សម្រាប់ជំណាច់ការិយបរិច្ឆេទ 3ខែ និង 9ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021**

## 4. ការប្តូររូបិយប័ណ្ណប្រាក់ដុល្លារអាមេរិកទៅប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីអនុវត្តទៅតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រា នាកាលបរិច្ឆេទរាយការណ៍។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល និងរបាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូរប្រាក់ដូចខាងក្រោម៖

| | | អត្រានាកាលបរិច្ឆេទរាយការណ៍ | អត្រាមធ្យមការិយបរិច្ឆេទ 9ខែ | អត្រាមធ្យមការិយបរិច្ឆេទ 3ខែ |
|---|---|---|---|---|
| ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021 | 1 ដុល្លារអាមេរិក = | 4,079រៀល | 4,066រៀល | 4,076រៀល |
| ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2020 | 1 ដុល្លារអាមេរិក = | 4,100រៀល | 4,082រៀល | 4,095រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | 1 ដុល្លារអាមេរិក = | 4,045រៀល | គ្មាន | គ្មាន |

តួលេខជាប្រាក់រៀលនេះ គឺសម្រាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិកនេះត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

## 5. បម្រែបម្រួលតាមរដូវកាលនៃប្រតិបត្តិការអាជីវកម្ម

សកម្មភាពចម្បងរបស់ក្រុមហ៊ុន ជាទូទៅពាក់ព័ន្ធនឹងការផ្តល់សេវាឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗ ដល់ប្រជាពលរដ្ឋ សហគ្រាសធនតូច និងមធ្យម ព្រមទាំងចូលរួមក្នុងរាល់សកម្មភាពផ្សេងៗទៀត ដែលគាំទ្រដល់កម្មវត្ថុទាំងនេះ។ ពុំមានបច្ច័យដែលនាំឲ្យមានបម្រែបម្រួលតាមរដូវកាលនៃប្រតិបត្តិការអាជីវកម្ម ដែលមានលក្ខណៈជាសារវន្ត ដែលពាក់ព័ន្ធនឹងសកម្មភាពធុរកិច្ចទាំងនេះទេ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 9ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021

### 6. សាច់ប្រាក់ក្នុងដៃ

| | *ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2021* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| ទីស្នាក់ការកណ្តាល | 38,411,169 | 156,679,158 | 43,578,608 | 176,275,469 |
